វគ្គបំប៉នថ្នាក់ទី១២

# អត្ថាធិប្បាយពន្យល់អក្សរសិល្ប៍ ប្រធានទី៣

**វ៉ាន់ វី**

សាស្ត្រាចារ្យជំនួយ

នៅដេប៉ាតឺម៉ង់ភាសាវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១៤ កក្កដា ២០២៤

# មាតិកា

- ប្រធានទី៣
- គម្រោងតែង
- សេចក្តីអធិប្បាយ

**ប្រធានទី៣៖** មានទស្សនៈលើកឡើងថា “**ការទទួលយកពាក្យសត្យរបស់នាងកៃកេសី ជាពលិកម្មដ៏ធំធេងរបស់ព្រះរាម**”។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងរឿងរាមកេរ្តិ៍មកបញ្ជាក់។

# គម្រោងតែង

## ១- សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ ផ្ដើមពីរឿងរ៉ាវកើតឡើង
- ចំណូលបញ្ហា៖ ដាក់មតិប្រធាន
- ចំណោទបញ្ហា៖ ចោទបែបប្រធានពន្យល់

## ២- តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី + ពន្យល់ពាក្យគន្លឹះ + ពន្យល់ន័យប្រធាន
- បកស្រាយប្រធាន៖ គំនិតសំខាន់និងអំណះអំណាង
- សរុប

## ៣- សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន
- មតិផ្ទាល់ខ្លួន

# សេចក្តីអធិប្បាយ

នៅភាគខាងដើមនៃរឿងរាមកេរ្តិ៍ខ្មែរ អ្នកនិពន្ធបានបង្ហាញពីទំនាស់ដ៏តានតឹងមួយក្នុងរាជវង្ស គឺរវាងបំណងរបស់ព្រះបាទទសរថ ដែលចង់ឱ្យព្រះរាមឡើងសោយរាជ្យតាមប្រពៃណីក្សត្រ និងការតវ៉ារបស់នាងកៃកេសីឲ្យព្រះអង្គគោរពតាមពាក្យសត្យដែលធ្លាប់សន្យា ដោយតម្រូវឱ្យបុត្ររបស់ព្រះនាងឡើងសោយរាជ្យវិញ។ ដើម្បីបញ្ចប់ទំនាស់ ព្រះរាមសម្រេចព្រះទ័យគោរពតាមពាក្យសត្យនេះ ដោយយាងចេញពីនគរចំនួយដប់បួនឆ្នាំទៅបួសក្នុងព្រៃតាមសំណូមពរនាងកៃកេសី។ ដោយមើលឃើញឥរិយាបថព្រះរាមដូចខាងលើនេះហើយ ទើបមានទស្សនៈលើកឡើងថា “**ការទទួលយកពាក្យសត្យរបស់នាងកៃកេសី ជាពលិកម្មដ៏ធំធេងរបស់ព្រះរាម**”។

តើទស្សនៈមានអត្ថន័យយ៉ាងដូចម្តេច?

ដើម្បីបានជាទុនក្នុងការបកស្រាយមតិប្រធានខាងលើនេះឲ្យកាន់តែស៊ីជម្រៅ គប្បីស្វែងយល់ន័យនៃពាក្យខ្លះជាមុនសិន ។ **“ពាក្យសត្យ”** ក្នុងទីនេះ សំដៅដល់ពាក្យពិត ឬពាក្យទៀងត្រង់ ដែលគេបានប្រកាសរួចហើយពីបំណងណាមួយរបស់ខ្លួននៅពោះមុខនរណាម្នាក់ឬវត្ថុអ្វីមួយទុកជាសាក្សី។ ចំណែក **“ពលិកម្ម”** មានន័យថា ការបូជាឬការលះបង់ដើម្បីបុព្វហេតុអ្វីមួយដែលជាប្រយោជន៍ដល់អ្នកដទៃឬសង្គមជាតិ។ **ដូចនេះ គំនិតប្រធានខាងលើចង់មានន័យថា ការព្រមធ្វើតាមពាក្យពិតរបស់នាងកៃកេសីរំលឹកតវ៉ានឹងព្រះបាទទសរថ គឺជាការលះបង់ដ៏ធំធេងរបស់តួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ខ្មែរ ។**

ពិតណាស់ បើពិនិត្យមើលដំណើររឿងរាមកេរ្តិ៍ត្រង់ខ្សែទី១ យើងប្រាកដជាឃើញថា មានបញ្ហាទំនាស់ដ៏តឹងតែងមួយក្នុងរាជវង្សបន្ទាប់ពីព្រះរាមនិងនាងសីតាអភិសេករួច។ តាមប្រពៃណីក្សត្រ ព្រះបាទទសរថត្រូវលើកព្រះរាមជាបុត្រច្បងឱ្យឡើងស្នងរាជ្យ។ ប៉ុន្តែ ខណៈនោះ នាងកៃកេសីជំទាស់ពុំព្រម ដោយទូលសុំឱ្យរាជបុត្រព្រះនាង គឺព្រះភិរុតសោយរាជ្យវិញ គឺតម្រូវតាមពាក្យសត្យដែលព្រះបាទទសរថធ្លាប់សន្យានឹងនាងថា "ច្បាំងឈ្នះព្រះអាទិត្យសុរិយា ស្តេចបានប្តេជ្ញា ពាក្យសត្យនឹងអញខ្ញុំហោង។ ថានូវឲ្យរាជ្យព្រះភិរុតគ្រង សោយរាជ្យសម្បត្តិស្នង ព្រះបាទសម្តេចរាជា"។ ការណ៍នេះបាននាំឱ្យព្រះបាទទសរថពិបាកសម្រេចព្រះទ័យជាខ្លាំង។ ព្រះអង្គក៏ស្នើឱ្យបែងចែកនគរជាពីរ មួយឲ្យព្រះរាមគ្រងរាជ្យតាមប្រពៃណីក្សត្រ មួយទៀតឲ្យព្រះភិរុតគ្រងរាជ្យតាមពាក្យសត្យ។ ប៉ុន្តែ នាងកៃកេសីនៅតែពុំព្រម ហើយថែមទាំងទូលសុំឱ្យព្រះរាមនិងព្រះលក្ស្មណ៍យាងទៅបួសជាឫសីនៅព្រៃប្អូនដណ្តប់ឆ្នាំទៀត។ ដើម្បីបញ្ចប់ទំនាស់នេះ ព្រះរាមសម្រេចព្រះទ័យគោរពពាក្យសត្យរបស់ព្រះបិតាដែលធ្លាប់សន្យា និងព្រមយាងចេញពីនគរចំនួនដប់បួនឆ្នាំទុករាជ្យបល្ល័ង្កឲ្យព្រះភិរុតគ្រងរាជ្យ។

ការសម្រេចព្រះទ័យព្រះរាមដូចខាងលើ គឺជាពលិកម្មដ៏ឧត្តុង្គឧត្តម ស្ទើរតែពុំមានបុគ្គលណាមួយអាចបំពេញបាន។ ត្រង់នេះសបញ្ជាក់ថា ព្រះរាមពិតជាធ្វើពលិកម្មដ៏ធំធេងមួយ ពុំមែនដើម្បីខ្លួនឯងទេ គឺលះបង់ដើម្បីបុព្វច្រើនយ៉ាង។ បុព្វហេតុទីមួយ គឺព្រះរាមចង់តបស្នងសងគុណព្រះបាទទសរថជាព្រះបិតា។ ដូចឃើញស្រាប់ហើយថា ព្រះបាទទសរថមានទុក្ខព្រួយនិងរងសម្ពាធជាខ្លាំងនៅពេលនាងកៃកេសីជំទាស់មិនព្រមឱ្យព្រះរាមឡើងស្នងរាជ្យតាមច្បាប់នគរ ធ្វើរាជវង្សច្របូកច្របល់។ ក្នុងនាមជារាជបុត្រច្បង ព្រះរាមពុំអាចទ្រាំឈរមើលព្រះបិតារបស់ទ្រង់វិយោគសោយសោកទេ។ ហេតុនេះ ទើបព្រះអង្គចេញមុខទទួលខុសត្រូវចំពោះរឿងអតីតកាលរបស់ព្រះបិតា ដើម្បីសម្តែងនូវកតញ្ញូតាធម៌ចំពោះអ្នកមានគុណ។ មិនតែប៉ុណ្ណោះ ព្រះអង្គក៏ពុំបានខឹងសម្បារអ្វីនឹងនាងកៃកេសី ដែលត្រូវជាមហេសីបន្ទាប់របស់ព្រះបិតាទ្រង់ដែរ។ ជាក់ស្តែង ត្រង់កន្លែងព្រះលក្ស្មណ៍ក្រោធខឹងប៉ងទៅពិឃាតនាកៃកេសី ព្រះរាមពោលឃាត់ “ថាហៃវរលក្ស្មណ៍កុំបីបា គិតចងទោសា នឹងអ្នកដ៏មានគុណ។ អំពើនោះបាបធ្ងន់ក្រៃ កុំធ្វើចោះនៃ ចូរបារំសាយក្រោធា”។ នេះសឲ្យឃើញថា ព្រះអង្គមានទឹកព្រះទ័យកតញ្ញូចំពោះអ្នកមានគុណណាស់។

ក្រោយអំពីនេះ ព្រះរាមធ្វើពលិកម្មបែបនេះ ក៏ព្រោះតែបុព្វហេតុពុំចង់ឱ្យព្រះរាជវង្សបែកបាក់។ តាមដំណើររឿង យើងឃើញថា ព្រះរាមព្រះលះបង់រាជ្យសម្បត្តិឲ្យទៅព្រះអនុជ គឺព្រះភិរុត បើទោះបីតាមច្បាប់នគរ ព្រះអង្គត្រូវឡើងស្នងរាជ្យក្ដី។ ទង្វើនេះក៏ជាគុណធម៌ដ៏ប្រពៃចំពោះព្រះអនុជ គឺក្នុងនាមជាព្រះជេដ្ឋា ព្រះរាមហ៊ានលះបង់ដើម្បីប្អូន ហើយពុំចង់ឲ្យបងប្អូនបែកបាក់គ្នាព្រោះតែតំណែងនោះទេ។ តាមដំណើររឿង ក្រោយពេលព្រះភិរុតដឹងរឿងនេះ ព្រះអង្គខឹងសម្បារនឹងព្រះមាតាជាខ្លាំង ហើយទៅតាមរកព្រះរាមមកគ្រងរាជ្យវិញ តែព្រះអង្គនៅតែគោរពតាមពាក្យសត្យ ដោយឲ្យព្រះអនុជមកគ្រប់គ្រងនគរវិញ ដោយប្រទានព្រះសុពណ៌បាទ ដើម្បីទុកជានិមិត្តរូបនៃការសោយរាជ្យដល់ព្រះភិរុតតែប៉ុណ្ណោះ។ នេះគឺជាការលះបង់ដ៏ធំធេងរបស់ព្រះរាមចំពោះព្រះរាជវង្ស ក៏ដូចជាព្រះអនុជរបស់ទ្រង់។

លើសពីនេះទៅទៀត ការលះបង់របស់ព្រះរាម ដើម្បីផលប្រយោជន៍ព្រះនគរទាំងមូល។ ប្រសិនបើព្រះរាមមិនទទួលយកពាក្យសត្យខាងលើនេះទេ ព្រះនាងកៃកេសីក៏នៅតែជំទាស់នឹងព្រះបាទទសរថ  អាចបង្កឲ្យមានសង្គ្រាមបង្ហូរឈាមនឹងកើតឡើងរវាងអ្នកគាំទ្រខាងព្រះអង្គនិងអ្នកគាំទ្រខាងព្រះនាងកៃកេសីជាពុំខាន។ ព្រះអង្គពុំចង់ឃើញព្រះនគររបស់ទ្រង់ត្រូវហែកហួរដោយសារតែការដណ្ដើមតំណែងគ្នានោះទេ។ ជាការពិត ប្រសិនបើជម្លោះនៅតែបន្ត ហើយសង្គ្រាមកើតឡើងមែននោះ អ្នកដែលត្រូវរងទុក្ខពិតប្រាកដក្នុងរឿងនេះ គឺប្រជារាស្ត្រ។ នេះមានន័យថា ប្រជារាស្ត្រអាចត្រូវគេកេណ្ឌយកទៅធ្វើជាទ័ពច្បាំងគ្នា ដើម្បីការពារអំណាចបុគ្គល។ ចំណែករាស្ត្រស្លូតត្រង់ក៏នឹងត្រូវរងក្ដីវេទនាដោយសារសង្គ្រាមដែរ។  អំណាចដែលកើតឡើងដោយឈាមនិងទឹកភ្នែកប្រជារាស្ត្រពិតជាគ្មានតម្លៃឡើយ ។ ត្រង់នេះសឲ្យឃើញពីគុណធម៌របស់ព្រះរាម ដែលសក្តិសមជាមេដឹកនាំដ៏ល្អ ព្រោះព្រះអង្គចង់ឃើញនគរមានសន្តិភាព ប្រជារាស្ត្ររស់នៅសុខសាន្ត។

សរុបសេចក្ដីមក ការទទួលយកពាក្យសត្យរបស់នាងកៃកេសី ពិតជាបង្ហាញឲ្យឃើញថា ព្រះរាមបានលះបង់ខ្ពស់ពិតប្រាកដមែន គឺជាការដោះស្រាយតាមសន្តិវិធី ក្នុងបុព្វហេតុជាប្រយោជន៍ ដើម្បីអ្នកមានគុណ ដើម្បីព្រះរាជវង្ស និងដើម្បីសុខទុក្ខរបស់ព្រះនគរទាំងមូល។

ឆ្លងតាមការបកស្រាយខាងលើនេះ យើងអាចនិយាយបានថា ទស្សនៈប្រធានពិតជាមានអត្ថន័យដ៏ល្អជ្រាលជ្រៅ ព្រោះបានអប់រំមនុស្សគ្រប់រូបឲ្យចេះលះបង់ ចេះកាត់បន្ថយអត្តទត្ថប្រយោជន៍ ដើម្បីជាប្រយោជន៍ដល់សង្គមគ្រួសារនិងសង្គមជាតិ ។ ម្យ៉ាងទៀត គំនិតប្រធានក៏បានបណ្ដុះស្មារតីសន្តិភាពចំពោះអ្នកសិក្សាឲ្យចេះលះបង់ ដើម្បីកុំឱ្យមានជម្លោះឬសង្គ្រាមកើតមានឡើង។ ហេតុនេះ យើងជាអ្នកសិក្សាគាប្បីរៀនសូត្រតាមគំរូវីរភាពរបស់តួអង្គព្រះរាម ដែលហ៊ានលះបង់រាជ្យសម្បត្តិ ដើម្បីប្រយោជន៍រួម និងដើម្បីសន្តិភាព។

# ឯកសារពិគ្រោះ

កាន់ ចាន់ដារ៉ា និង វ៉ាន់ វី *តែងសេចក្ដី៖ ប្រធានពន្យល់* ភ្នំពេញ ឆ្នាំ២០១២។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាទុតិយភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាបឋមភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។

សែម សូវ, ថោង ផែល និងអ្នកដទៃទៀត ***វិញ្ញាសាតែងសេចក្ដីគំរូ*** បណ្ណាគារមាឃើង ឆ្នាំ១៩៧១។